

# មតិស្វាគមន៍របស់ ឯកឧត្តមឯកអគ្គរាជទូត គូរ៉ូគី ម៉ាសាហ៊្វមី !

សូមស្វាគមន៍មកកាន់គេហទំព័រស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ។ រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះប្រទេសកម្ពុជាទទួលបាននូវស្ថិរភាពនយោបាយ និង ការកសាងប្រទេសឡើងវិញក្នុងកម្រិតមួយគួរអោយកត់សម្គាល់។ ជាមួយនិងសង្គមដែលមានភាពរស់រវើក និងការពង្រីកនូវសេដ្ឋកិច្ចដ៏ពេញចិត្តរបស់ខ្លួន បច្ចុប្បន្ន ប្រទេសនេះកំពុងបង្ហាញនូវបម្លាស់ប្តូរបន្ថែមទៀត។ ក្នុងនាមជាតំណាងមួយនៃប្រទេសជប៉ុន ខ្ញុំមានកិត្តិយសក្នុងការទទួលខុសត្រូវចំពោះទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុននាអំឡុងពេលដ៏រីករាយនេះ។

ទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា និង ប្រទេសជប៉ុនត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥៣។ ជាពិសេសចាប់តាំងពីដើមឆ្នាំ១៩៩០ ប្រទេសជប៉ុនបានផ្តល់នូវជំនួយឧបត្ថម្ភផ្សេងៗដល់ការកសាង និង អភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញ ដូចជាការចូលរួមចំណែកជាលើកដំបូងបំផុតដោយកងកំលាំងស្វ័យការពារប្រទេសជប៉ុននៅក្រៅប្រទេស ក្នុងផ្នែកមួយនៃដំណើរការរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ ការអនុវត្តន៍គម្រោងឧបត្ថម្ភគាំទ្រដោយរដ្ឋាភិបាលជប៉ុន និងអង្គការក្រៅរដ្ឋាភិបាល កិច្ចសហប្រតិបត្តិការអភិរក្ស និងជួសជុលស្តារឡើងវិញនូវប្រាសាទអង្គរ ព្រមទាំងការចូលរួមចំណែកដល់ការបង្កើតអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជាជាដើម។

ឥឡូវនេះ ប្រទេសជប៉ុនកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍន៍តំបន់ទន្លេមេគង្គ រួមទាំងប្រទេសកម្ពុជា និង ផ្តោតទៅលើការពង្រឹងទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសក្នុងតំបន់។ បើពិនិត្យទៅលើកិច្ចព្រមព្រៀងស្តីអំពីសេរីភាវូបនីយកម្ម ជម្រុញ និងការពារការវិនិយោគរវាងជប៉ុន និង កម្ពុជា ដែលបានចូលជាធរមាននៅឆ្នាំ២០០៨ ខ្ញុំចង់ឃើញនូវទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសយើងទាំងពីរត្រូវបានជម្រុញ។

ស្ថានទូតជប៉ុន រួមជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ក្រុមហ៊ុនជប៉ុន ព្រមទាំងជនជាតិជប៉ុននៅប្រទេសកម្ពុជា នឹងខិតខំប្រឹងប្រែងពង្រឹងបន្ថែមនូវចំណងទ្វេរភាគីរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុន។ ខ្ញុំក៏សូមស្វាគមន៍ដល់ប្រជាជនជប៉ុនដែលនៅក្រៅប្រទេសកម្ពុជាក្នុងការអញ្ជើញមកធ្វើទស្សនកិច្ច និងធ្វើការជាមួយពួកយើងនៅទីនេះ ដើម្បីជម្រុញទំនាក់ទំនងជាមិត្តភាពសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរ។

**គូរ៉ូគី ម៉ាសាហ៊្វូមី**
**ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព**